# ពិធីការសម្រាប់បារ (Bars)៖ ឧបសម្ព័ន្ធ Y-1

## កាលបរិច្ឆេទមានប្រសិទ្ធភាព៖ ម៉ោង 12:01 រំលងអាធ្រាតថ្ងៃព្រហស្បតិ៍ ទី6 ខែឧសភាឆ្នាំ 2021

**បច្ចុប្បន្នភាពថ្មីៗ** (ការផ្លាស់ប្តូរត្រូវបានរំលេចដោយពណ៌លឿង)

**5/5/2021:**

- បារអាចបើកទទួលភ្ញៀវនៃសេវានៅខាងក្នុងអគារបាន។ ទីតាំងខាងក្នុងអគារត្រូវបានកំណត់ចំនួនត្រឹម 25%ជាអតិបរមានៃទីតាំងទាំងមូល ឬចំនួនមនុស្ស ត្រឹម100នាក់ យកមួយណាដែលតិចជាងតាមការកែសម្រួលជាក់ស្តែង។
- តម្រូវការសម្រាប់ការរៀបចំកន្លែងអង្គុយនៅខាងក្នុងនិងក្រៅអគារត្រូវបានបញ្ជាក់បន្ថែមឱ្យបានច្បាស់លាស់។
- ទូរទស្សន៍អាចបើកទាំងនៅក្នុង និងខាងក្រៅនៃទីតាំងបរិភោគអាហារ។
- តន្ត្រីកម្សាន្តបន្តផ្ទាល់ត្រូវបានអនុញ្ញាតតែនៅខាងក្រៅអគារតែប៉ុណ្ណោះ។ ការកម្សាន្តបន្តផ្ទាល់នៅខាងក្នុងអគារមិនត្រូវបានអនុញ្ញាតទេ។

ករណីចំនួនអ្នកជំងឺ COVID-19 ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងចំនួនអ្នកស្លាប់មានការថយចុះខ្លះ ហើយហាក់ដូចជាមានស្ថេរភាព ប៉ុន្តែជំងឺCOVID-19 បន្តបង្កហានិភ័យខ្ពស់ដល់សហគមន៍ និង តម្រូវឱ្យមនុស្សនិងអាជីវកម្មទាំងអស់ត្រូវមានការប្រុងប្រយ័ត្ន និងកែប្រែប្រតិបត្តិការ និងសកម្មភាពដើម្បីកាត់បន្ថយ ហានិភ័យនៃការរីករាលដាល។

ដោយសារតែខោនធី Los Angeles ចាត់ចូលទៅក្នុង "ចំណាត់ពណ៌លឿង" ("Yellow Tier") នៃក្របខ័ណ្ឌផែនការរបស់រដ្ឋសម្រាប់ក្របខ័ណ្ឌសេដ្ឋកិច្ចដែលមានសុវត្ថិភាព ពិធីការនេះត្រូវបានរៀបចំបន្ថែមទៀតដើម្បីដកការរឹតត្បិតសកម្មភាពដោយលាក់មួយចំនួនក្នុងតំបន់។ អាជីវកម្មទាំងអស់គួរតែបើកដំណើរការដោយមានការប្រុងប្រយ័ត្នខ្ពស់ និងប្រកាន់ខ្ជាប់នូវតម្រូវការនៅក្នុងពិធីការនេះ ដើម្បីកាត់បន្ថយសក្តានុពលនៃការរីករាលដាលជំងឺ COVID-19 នៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ពួកគេ។

ពិធីការ និងតម្រូវការផ្សេងៗខាងក្រោមមានលក្ខណៈជាក់លាក់ចំពោះការបើកឱ្យដំណើរការបារឡើងវិញ ដែលត្រូវបានអនុញ្ញាតដោយនាយកដ្ឋានសុខភាពសាធារណៈខោនធីLos Angelesជាប្រភេទភោជនីយដ្ឋានដែលមានហានិភ័យទាប។

- បារដែលផ្តល់ជូនសេវាកម្មអាហារនៅនឹងទីកន្លែងតែម្តងត្រូវតែប្រកាន់ខ្ជាប់នូវតម្រូវការទាំងអស់សម្រាប់ការទទួលទានអាហារ មាននៅក្នុង [ពិធីការសម្រាប់ភោជនីយដ្ឋាន៖ ឧបសម្ព័ន្ធ I]។ បារដែលបច្ចុប្បន្នទទួលបានការអនុញ្ញាតឱ្យលក់ស្រាបៀរ ស្រា ឬគ្រឿងស្រវឹងផ្សេងៗទៀតដែលត្រូវទទួលទានក្រៅពីបរិវេណនេះគឺតម្រូវឱ្យអនុវត្តតាម[ពិធីការសម្រាប់អាជីវកម្មលក់រាយ៖ ឧបសម្ព័ន្ធ B]។
- បារត្រូវតែបញ្ឈប់ប្រតិបត្តិការល្បែងផ្សេងៗ រួមមានតែមិនកំណត់ចំពោះ ការបោះប៉ូ ក្តាគប់ព្រួញ តុប៊ុកប៊ីយ៉ែ និងប្រភេទល្បែងដទៃទៀត ប៉ុន្តែកំតែសកម្មភាពទាំងនេះត្រូវបានអនុញ្ញាតឱ្យបើកនៅក្នុងប្រតិបត្តិការដែលមានការកែប្រែ ឬ អនុញ្ញាតប្រតិបត្តិការបានពេញលេញ។
- ហាងស្រា និងរោងស្រាបៀរដែលផលិតស្រាឬស្រាបៀរដោយមានបរិវេណកំណត់សម្រាប់ការភ្លក់ស្រាឬស្រាបៀរត្រូវបានដកចេញពីនិយមន័យនៃទីតាំងអាហារដោយក្រមសុខភាពនិងសុវត្ថិភាពរដ្ឋ California ចុះលេខ 113789 (c) (5) ដែលមិនតម្រូវឱ្យមានការអនុញ្ញាតលើការអនុវត្តផ្នែកសុខភាពដើម្បីប្រតិបត្តិការឡើយ ដោយតម្រូវឱ្យអនុវត្តតាមពិធីការសម្រាប់ [ហាងស្រាបៀរ, ម៉ាស៊ីនស្រា, និងម៉ាស៊ីនចំរាញ់សិប្បកម្ម]។
- បារអាចរៀបចំព្រឹត្តិការ ឬការសម្តែងផ្ទាល់ដែលមានការអង្គុយនៅខាងក្រៅអគារដោយអនុលោមតាម[ពិធីការសម្រាប់ព្រឹត្តិការណ៍ និងការសម្តែងដែលមានកន្លែងអង្គុយនៅខាងក្រៅអគារ]របស់ LA County DPH។

បារទាំងអស់ដែលដំណើរការដោយអនុលោមតាមពិធីការនេះអាចត្រូវបានបើកសម្រាប់សេវាកម្មខាងក្រៅអគារនិងសេវាកម្មនៅខាងក្នុងអគារកំណត់ត្រឹមតែមនុស្សចំនួន25%នៃទីតាំងទាំងមូល ឬ100នាក់ប៉ុណ្ណោះ យកមួយណាដែលតិចជាងតាមការកែសម្រួលជាក់ស្តែងដែលជាតម្រូវការនៃពិធីការនេះ។

មេរោគ COVID-19 ភាគច្រើនឆ្លងរាលដាលនៅពេលដែលមានមនុស្សនៅជិតអ្នកដែលមានជំងឺ COVID-19 ឬបានប៉ះពាល់ដោយផ្ទាល់ជាមួយបុគ្គលរូបនោះ។ នៅពេលដែលអ្នកមានជំងឺ COVID-19 បានក្អក កណ្តាស់ ច្រៀង និយាយ ឬដកដង្ហើម ពួកគេបញ្ចេញតំណក់ទឹកតូចៗតាមផ្លូវដង្ហើម។ ហើយយោងទៅតាមមជ្ឈមណ្ឌលត្រួតពិនិត្យ និងបង្ការជំងឺ ហានិភ័យនៃការរីករាលដាលជំងឺ COVID-19 អាចកើនឡើងគ្រប់បរិបទ ក្នុងករណីដែលបុគ្គលម្នាក់ៗដោះម៉ាស់ចេញ ខណៈពេលបរិភោគអាហារ និង ភេសជ្ជៈ ហើយពេលណាមានការកើនឡើងនូវការទំនាក់ទំនងគ្នារវាងមនុស្សដែលមិនមែនជាមនុស្សដែលរស់នៅក្នុងគ្រួសារតែមួយ។

- **ហានិភ័យទាបបំផុត៖** សេវាកម្មអាហារ/ភេសជ្ជៈត្រូវបានកំណត់ត្រឹមការទិញដោយបើកបរឆ្លងចាត់ ការដឹកជញ្ជូន ការទិញដោយខ្ចប់ និងការបញ្ជាទិញតាមអនឡាញហើយមកទទួលយកដោយខ្លួនឯង។
- **ហានិភ័យខ្ពស់៖** ការទិញដោយបើកបរឆ្លងចាត់ ការដឹកជញ្ជូន ការទិញដោយខ្ចប់ និងការបញ្ជាទិញតាមអនឡាញហើយមកទទួលយកដោយខ្លួនឯងត្រូវបានលើកកំពស់។ សេវាកម្មបរិភោគអាហារ/ភេសជ្ជៈនៅទីឯកន្លែងត្រូវបានដាក់កំណត់ដោយមានកន្លែងអង្គុយនៅខាងក្រៅអគារ។ ចំនួនផ្ទុកនៃកន្លែងអង្គុយត្រូវតែកាត់បន្ថយដើម្បីរៀបកុឱ្យមានចន្លោះដាច់ពីគ្នា។
- **ហានិភ័យកាន់តែខ្ពស់៖** ការទទួលទានអាហារ ឬភេសជ្ជៈដោយចំនួនផ្ទុកនៃកន្លែងអង្គុយនៅខាងក្នុងអគារត្រូវកាត់បន្ថយដើម្បីរៀបកុឱ្យមានចន្លោះដាច់ពីគ្នា។ និង/ឬការទទួលទានអាហារ ឬភេសជ្ជៈដោយកន្លែងអង្គុយនៅខាងក្រៅអគារ ប៉ុន្តែមិនចាំបាច់រៀបកុឱ្យមានចន្លោះដាច់ពីគ្នា។
- **ហានិភ័យខ្ពស់បំផុត៖** ការទទួលទានអាហារ ភេសជ្ជៈដោយកន្លែងអង្គុយនៅខាងក្នុងអគារ ចំនួនផ្ទុកនៃកន្លែងអង្គុយមិនអាចកាត់បន្ថយបាន ហើយមិនរៀបកុឱ្យមានចន្លោះដាច់ពីគ្នា។

នៅក្នុងពិធីការដែលអនុវត្តតាម ពាក្យ "គ្រួសារ" គឺមានន័យថា "មនុស្សដែលរស់នៅជាមួយគ្នាក្រោមដំបូល តែមួយ" ហើយមិនត្រូវរាប់បញ្ចូលទាំងស្ថានភាពរស់នៅជាក្រុមរួមស្ថាប័ន ដូចជាអន្តេវាសិកដ្ឋាន សមាគមបុរស សមាគមស្ត្រី វត្តអារាម អារាសដូនជី ឬលំនៅដ្ឋានថែទាំ ហើយក៏មិនរួមបញ្ចូលទាំងការរស់នៅបែបពាណិជ្ជកម្ម ដូចជាផ្ទះជួលសមាគមន៍ សណ្ឋាគារ ឬផ្ទះសំណាក់[1]។ ពាក្យ" បុគ្គលិក" និង" និយោជិក" មានន័យដើម្បីរួមបញ្ចូល និយោជិក អ្នកស្ម័គ្រចិត្ត អ្នកហាត់ការ និងសិក្ខាកាម បញ្ញវ័ន្ត និងបុគ្គលដទៃទៀត ដែលបំពេញការងារនៅទីឯកន្លែង។ ពាក្យ "អ្នកទស្សនា" ឬ "អតិថិជន" គួរតែត្រូវបានរាប់បញ្ចូលទាំងសមាជិកសាធារណៈ និងអ្នកផ្សេងទៀតដែលមិនមែនជាបុគ្គលិក ឬនិយោជិកដែលចំណាយពេលវេលានៅតាមអាជីវកម្ម ឬទីតាំងនេះដោយផ្ទាល់។ ពាក្យ "ទីតាំងអាជីវកម្ម" "ទីតាំង" និង "ទីកន្លែង" សំដៅលើអគារ និងអគារផ្ទាល់ដី ឬទីតាំងនៅជាប់គ្នា ដែលអនុញ្ញាតឲ្យមានសកម្មភាពផ្សេងៗ។ "LACDPH" គឺជានាយកដ្ឋានសុខភាពសាធារណៈរបស់ខោនធី Los Angeles។

នៅក្នុងពិធីការដែលអនុវត្ត បុគ្គលដែលត្រូវបានចាត់ទុកថា* "បានចាក់វ៉ាក់សាំងពេញលេញ"៖

- 2សប្តាហ៍ ឬច្រើនជាងនេះបន្ទាប់ពីពេលពួកគេទទួលបានការចាក់ដូសទីពីរ នៃប្រភេទវ៉ាក់សាំងCOVID-19ដែលមាន 2ដូស រួមមានPfizer -BioNTech ឬ Moderna ឬ
- 2សប្តាហ៍ ឬច្រើនជាងនេះបន្ទាប់ពីពេលពួកគេទទួលថ្នាំវ៉ាក់សាំងនៃប្រភេទដូសតែមួយដងរួចរាល់រួមមាន Johnson and Johnson [J&J]/Janssen។

*នេះត្រូវបានអនុវត្តចំពោះវ៉ាក់សាំង COVID-19 ដែលត្រូវបានអនុញ្ញាតសម្រាប់ការប្រើប្រាស់បន្ទាន់ ដោយរដ្ឋបាលចំណីអាហារ និងឱសថ Pfizer-BioNTech Moderna និង Johnson និង Johnson (J&J)/Janssen ។ ការណែនាំនេះត្រូវបានអនុវត្តចំពោះវ៉ាក់សាំងដែល )ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ជាបន្ទាន់ដោយអង្គការសុខភាពពិភពលោក (AstraZeneca/Oxford ខណៈពេលណាមួយ។ សូមចូលទៅកាន់ គេហទំព័ររបស់ WHO សម្រាប់ព័ត៌មានបន្ថែមអំពីវ៉ាក់សាំងដែលត្រូវបាន ទទួលស្គាល់ដោយអង្គការសុខភាពពិភពលោក (WHO)។

បន្ថែមលើលក្ខខ័ណ្ឌដែលដាក់សម្រាប់ការអនុវត្តនៅទីតាំងបារដោយមន្ត្រីសុខភាពសាធារណៈរដ្ឋ គ្រប់បារក៏ត្រូវតែគោរពតាមពិធីសារត្រួតពិនិត្យសុវត្ថិភាពនិងការគ្រប់គ្រងការចម្លងមេរោគទាំងនេះផងដែរ។

សូមចំណាំ៖ ឯកសារនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាពនៅពេលមានព័ត៌មាន ហើយប្រភពឯកសារទាំងនេះអាចមានសម្រាប់លោកអ្នក ដូច្នេះត្រូវប្រាកដថាបានពិនិត្យមើល តាមរយៈគេហទំព័រខោនធី LA http://www.ph.lacounty.gov/media/Coronavirus/ សម្រាប់ឯកសារថ្មីៗទាំងនេះ និងសេចក្តីណែនាំដែល។

បញ្ជីត្រូវផ្ទៀងផ្ទាត់នេះរួមមាន៖

[1] កូដ ខោនធី Los Angeles Title 22. §22.14.060 - F. និយមន័យគ្រួសារ (Ord. 2019-0004 § 1, 2019.) https://library.municode.com/ca/los_angeles_county/codes/code_of_ordinances?nodeId=TIT22PLZO_DIV2DE_CH22.14DE_22.14.060F

(1) គោលនយោបាយ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពនិយោជិក
(2) វិធានការណ៍ដើម្បីធានាការរក្សាគម្លាតរាងកាយ
(3) វិធានការណ៍ដើម្បីលើកកម្ពស់ការគ្រប់គ្រងការឆ្លងជំងឺ
(4) ការប្រាស្រ័យទាក់ទងជាមួយនិយោជិកនិងសាធារណជន
(5) វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព។

ចំណុចសំខាន់ៗទាំង ៥ នេះត្រូវតែអនុវត្តតាមនៅពេលដែលទីតាំងរបស់លោកអ្នករៀបចំពិធីការនៃការបើកឱ្យដំណើរការឡើងវិញ។

**អាជីវកម្មទាំងអស់ដែលគ្របដណ្តប់លើពិធីការនេះត្រូវអនុវត្តរាល់វិធានការណ៍ដែលអាចអនុវត្តបានដូចដែលមានរៀបរាប់ខាងក្រោម ហើយត្រូវត្រៀមខ្លួនដើម្បីពន្យល់ពីមូលហេតុដែលវិធានការណ៍ណាមួយមិនត្រូវបានអនុវត្ត ឬមិនអាចអនុវត្តចំពោះអាជីវកម្មនោះបាន។**

**ឈ្មោះអាជីវកម្ម៖**

**អាសយដ្ឋានទីតាំងអាជីវកម្ម៖** ______________________

**ចំនួនដែលផ្ទុកមនុស្ស នៃទំហំទីតាំងអាគារកាលពីមុន៖** ______________________

**ចំនួនកំណត់សម្រាប់ផ្ទុកមនុស្ស៖** ______________________

**កាលបរិច្ឆេទប្រកាស៖** ______________________

## A. គោលនយោបាយ និងការអនុវត្តនៅកន្លែងធ្វើការដើម្បីការពារសុខភាពនិយោជិក (សូមគូសធីកជ្រើសរើសគ្រប់ចំណុចដែលអនុវត្តនៅទីកន្លែងនេះ)

- ❑ មនុស្សគ្រប់គ្នាដែលអាចបំពេញកិច្ចការរបស់ខ្លួនពីផ្ទះ ត្រូវបានណែនាំឱ្យធ្វើដូច្នោះ។
- ❑ បុគ្គលិកដែលងាយរងគ្រោះ (បុគ្គលដែលមានអាយុលើសពី 65 ឆ្នាំ បុគ្គលដែលមានផ្ទៃពោះ និងបុគ្គលដែលមានស្ថានភាពសុខភាពរ៉ាំរ៉ៃ) ត្រូវបានចាត់ឱ្យទទួលការងារដែលអាចធ្វើពីផ្ទះនៅពេលដែលអាចអនុវត្តការងារនេះបាន ហើយគួរតែពិភាក្សាអំពីក្តីកង្វល់មួយចំនួនជាមួយអ្នកផ្តល់សេវាថែទាំសុខភាព ឬសេវាកម្មសុខភាពវិជ្ជាជីវៈរបស់ពួកគេដើម្បីធ្វើការសម្រេចចិត្តសមស្របលើការវិលត្រឡប់ទៅកន្លែងធ្វើការវិញនោះ។
- ❑ បុគ្គលិកទាំងអស់ត្រូវបានណែនាំកុំឲ្យមកធ្វើការ ប្រសិនបើមានជំងឺ ឬប្រសិនបើពួកគេត្រូវតម្រូវឱ្យធ្វើការនៅដាច់ពីគេ (ចត្តាឡីស័ក) បន្ទាប់ពី បានប៉ះពាល់នឹងមនុស្សដែលមានមេរោគជំងឺ COVID-19។
- ❑ ការត្រួតពិនិត្យច្រកចូល ត្រូវបានធ្វើឡើងមុនពេលបុគ្គលិក អ្នកលក់ដូរ និងបុគ្គលិកដឹកជញ្ជូនអាចចូលទៅកាន់ទីកន្លែងធ្វើការ ដោយអនុលោមតាមការណែនាំនៃ[ការត្រួតពិនិត្យច្រកចូល](#)របស់ LACDPH។ ការពិនិត្យនេះត្រូវតែពិនិត្យមើលលើស្ថានភាពពាក់ព័ន្ធនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងគ្រុនក្តៅ ឬគ្រុនរងា និងថាតើបុគ្គលនោះកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឱ្យនៅដាច់ដោយឡែក ឬការធ្វើចត្តាឡីស័ក (ដាក់ឱ្យដាច់ពីគេ) នាពេលថ្មីៗនេះ។ ការពិនិត្យទាំងនេះអាចត្រូវបានធ្វើពីចម្ងាយឬដោយផ្ទាល់នៅពេលនិយោជិកមកដល់។ ការត្រួតពិនិត្យសីតុណ្ហភាពក៏គួរតែត្រូវបានធ្វើនៅកន្លែងធ្វើការ ប្រសិនបើអាច។
  - ការត្រួតពិនិត្យទទួលលទ្ធផលអវិជ្ជមាន (មិនមានបញ្ហា)។ ប្រសិនបើបុគ្គលនោះមិនមានរោគសញ្ញា និងគ្មានការប៉ះពាល់ជាមួយករណីជំងឺ COVID-19 ដែលបានរកឃើញក្នុងរយៈពេល 10 ថ្ងៃចុងក្រោយនេះទេ ពួកគេគឺមិនមានបញ្ហា ហើយអាចចូលទៅទីតាំងបានសម្រាប់ថ្ងៃនោះ។
  - ការត្រួតពិនិត្យទទួលលទ្ធផលវិជ្ជមាន (មានបញ្ហា)៖
    - ប្រសិនបើបុគ្គលនោះមិនបានទទួលវ៉ាក់សាំង[2]ប្រឆាំងជំងឺ COVID-19គ្រប់ចំនួនទេ ហើយបានប៉ះពាល់នឹងករណីមេរោគ COVID-19ដែលបានរកឃើញក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ឬថ្មីៗនេះ ស្ថិតនៅក្រោមការដាក់ឱ្យនៅដាច់ពីគេ ពួកគេមិនអាចចូល

---

[2] បុគ្គលដែលត្រូវបានគេចាត់ទុកថាបានចាក់វ៉ាក់សាំងប្រឆាំងមេរោគCOVID-19គ្រប់ចំនួនគឺគិតចាប់ពីពីរ (2) សប្តាហ៍ឬច្រើនជាងនេះបន្ទាប់ពីពេលពួកគេទទួលបានការចាក់ដូសទីពីរ នៃប្រភេទវ៉ាក់សាំង (រួមមានPfizer -BioNTech ឬ Moderna) ឬពីរ (2) សប្តាហ៍ ឬច្រើនជាងនេះបន្ទាប់ពីពេលពួកគេទទួលថ្នាំវ៉ាក់សាំងនៃ ប្រភេទដូសតែមួយដងរួចរាល់ហើយ (រួមមាន Johnson and Johnson [J&J]/Janssen) ។

ឬធ្វើការនៅទីតាំងនេះបានទេ ហើយត្រូវតែបញ្ជូនទៅផ្ទះភ្លាមៗ ដើម្បីដាក់ឱ្យនៅដាច់ពីគេនៅក្នុងផ្ទះ។ ផ្តល់ជូនពួកគេនូវការណែនាំនៃការធ្វើ ចត្តាឡីស័ក (ដាក់ឱ្យនៅដាច់ពីគេ) តាមតំណភ្ជាប់ ph.lacounty.gov/covidquarantine។

- ប្រសិនបើបុគ្គលនោះមានរោគសញ្ញាដូចបានបញ្ជាក់ខាងលើ ឬថ្មីៗនេះស្ថិតនៅក្រោមការដាក់ឱ្យនៅដាច់ដោយឡែក ពួកគេមិនអាចចូល ឬធ្វើការនៅទីតាំងនេះបានទេ ហើយត្រូវតែបញ្ជូនទៅផ្ទះភ្លាមៗដើម្បីដាក់ឱ្យនៅដាច់ដោយឡែក នៅក្នុងផ្ទះ។ ផ្តល់ជូនពួកគេនូវការណែនាំនៃការដាក់ឱ្យនៅដាច់ដោយឡែក តាមតំណភ្ជាប់ ph.lacounty.gov/covidisolation។

❑ ត្រូវផ្តល់ព័ត៌មានដល់បុគ្គលិកទាំងអស់អំពីអត្ថប្រយោជន៍នៃការឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិបាលចំពោះបុគ្គលិកអាចនឹងមានសិទ្ធិទទួលបាន អាចសម្រួលដល់ផ្នែកហិរញ្ញវត្ថុចំពោះបុគ្គលិកដែលចាំបាច់ត្រូវតែនៅផ្ទះ។ សូមមើលព័ត៌មានបន្ថែមអំពី កម្មវិធីរដ្ឋាភិបាលដែលគាំទ្រការសុំច្បាប់ឈប់សម្រាកឈឺ និងសំណងបុគ្គលិកសម្រាប់ជំងឺ COVID-19 រួមទាំងសិទ្ធិសុំច្បាប់ឈប់សម្រាកឈឺរបស់បុគ្គលិកក្រោមច្បាប់ស្តីពីច្បាប់ឈប់សម្រាកដោយជំងឺCOVID-19បន្ថែមនៅឆ្នាំ 2021។

❑ នៅពេលដែលទទួលព័ត៌មានថាមានបុគ្គលិកម្នាក់ ឬច្រើននាក់ ទទួលលទ្ធផលវិជ្ជមាននៃការធ្វើតេស្ត ឬមានរោគសញ្ញាដែលដូចគ្នាជាមួយជំងឺ COVID-19 (ករណី) និយោជកត្រៀមផែនការ ឬពិធីការឱ្យបានរួចរាល់ដើម្បីកំណត់ឱ្យករណីនេះអនុវត្តការដាក់ខ្លួនឱ្យនៅដាច់ដោយឡែកនៅផ្ទះ និងតម្រូវឱ្យមានការនៅដាច់ពីគេដោយខ្លួនឯងភ្លាមៗសម្រាប់បុគ្គលិកណាដែលមានការប៉ះពាល់ជាមួយករណីនៅកន្លែងធ្វើការនេះ។ គម្រោងផែនការរបស់និយោជកគួរតែពិចារណាពីពិធីការសម្រាប់បុគ្គលិកដែលធ្វើចត្តាឡីស័ក (នៅដាច់ពីគេ) ទាំងអស់ ដើម្បីអាចទទួលបាន ឬធ្វើតេស្តរកជំងឺ COVID-19 ដើម្បីកំណត់ថាតើមានការប៉ះពាល់នៅកន្លែងធ្វើការបន្ថែមទៀត ឬអត់ ដែលនេះអាចតម្រូវឱ្យមានវិធានការណ៍គ្រប់គ្រងជំងឺ COVID-19 បន្ថែម។ សូមមើលការណែនាំសុខភាពសាធារណៈស្តីពី ការឆ្លើយតបទៅនឹងជំងឺCOVID-19នៅកន្លែងធ្វើការ។

❑ នៅក្នុងករណីដែលម្ចាស់អាជីវកម្ម ប្រធានគ្រប់គ្រង ឬប្រតិបត្តិករដឹងថាបានរកឃើញមាន 3 ករណីឬច្រើនជាងនេះនៅកន្លែងធ្វើការក្នុងរយៈពេល 14 ថ្ងៃ នោះនិយោជក ត្រូវរាយការណ៍ពីការចម្លងជាចង្កោមនេះទៅនាយកដ្ឋានសុខភាពសាធារណៈតាមរយៈលេខ (888) 397-3993 ឬ (213) 240-7821 ឬ តាមតំណភ្ជាប់នេះ www.redcap.link/covidreport។ បើសិនជាចង្កោមត្រូវបានរកឃើញនៅកន្លែងធ្វើការ នាយកដ្ឋានសុខភាពសាធារណៈនឹងចាប់ផ្តើមការឆ្លើយតបចំពោះការឆ្លងជាក្រុម ដែលរួមមានដូចជាការផ្តល់ការណែនាំ និងអនុសាសន៍អំពីការគ្រប់គ្រងការឆ្លងជំងឺ ការគាំទ្រ បច្ចេកទេស និងវិធានការណ៍គ្រប់គ្រងដែលជាក់លាក់សម្រាប់ទីកន្លែង។ អ្នកគ្រប់គ្រងករណីសុខភាពសាធារណៈនឹងត្រូវបានចាត់តាំងដើម្បីធ្វើការស៊ើបអង្កេតការឆ្លងជាក្រុមដើម្បីដឹកនាំការឆ្លើយតបនៅទីកន្លែង។

❑ បុគ្គលិកដែលមានការប៉ះពាល់ជាមួយអ្នកដទៃនឹងទទួលបានម៉ាស់ ដោយឥតគិតថ្លៃ ដែលអាចពាក់សមទៅនឹងច្រមុះ និងមាត់។ សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រស្តីពីម៉ាស់ LAC DPH COVID-19 តាមរយៈ http://publichealth.lacounty.gov/acd/ncorona2019/masks។ បុគ្គលិកត្រូវពាក់ម៉ាស់គ្រប់ពេលវេលាក្នុងកំឡុងពេលធ្វើការនៅពេលមានទំនាក់ទំនងគ្នា ឬអាចប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ។ មានតែបុគ្គលិកដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្រថាពួកគេដែលមិនចាំបាច់ម៉ាស់តែត្រូវពាក់សន្ទះបាំងមុខដែលមានក្រណាត់នៅលើគែមខាងក្រោមដោយអនុលោមតាមការណែនាំរបស់រដ្ឋ ខណៈពេលដែលស្ថានភាពរបស់ពួកគេអាចធ្វើទៅបាន។ ក្រណាត់ដែលមានទ្រង់ទ្រាយពាក់បិទជាប់នៅក្រោមចង្កាត្រូវបានលើកទឹកចិត្តឱ្យប្រើ។ ម៉ាស់ដែលមានវ៉ាល់តែមួយផ្លូវមិនគួរប្រើទេ។

❑ បុគ្គលិកត្រូវបានណែនាំឲ្យប្រើប្រាស់និងថែរក្សាម៉ាស់បានត្រឹមត្រូវ រួមទាំងការពាក់វានៅលើច្រមុះនិងមាត់ និងតម្រូវឱ្យមានការបោកសម្អាត ឬប្តូរម៉ាស់របស់ពួកគេជារៀងរាល់ថ្ងៃ។

❑ របាំងមុខត្រូវបានផ្តល់ជូននិងពាក់ដោយបុគ្គលិករង់ចាំនិងបុគ្គលិកដទៃទៀតដែលមាន ឬអាចប៉ះពាល់ជាមួយអតិថិជន (នេះរួមបញ្ចូលប៉ុន្តែមិនកំណត់ចំពោះតែម្ចាស់អាជីវកម្ម អ្នកទទួលភ្ញៀវ និងបុគ្គលិករង់ចាំដែលមានទំនាក់ទំនងជាមួយអតិថិជនហើយក៏ដូចជានិយោជិកផ្សេងទៀតរួមមាន អ្នកបើកឡានក្រុង អ្នករត់ប្រណាំង និងមនុស្សផ្សេងៗទៀតដែលអាចចូលទីតាំងខាងមុខផ្ទះ) ។ របាំងមុខគឺត្រូវពាក់បន្ថែមពីលើម៉ាស់តែប៉ុណ្ណោះ។ ម៉ាស់ការពារអ្នកដទៃពីដំណក់ទឹកតូចៗដែលអាចចេញពីអ្នកពាក់នោះ របាំងមុខជួយការពារអ្នកពាក់ពីដំណក់ទឹកតូចដែលចេញពីអ្នកដទៃនោះ។ សន្ទះបាំងមុខគឺជាជម្រើសស្រេចចិត្តសម្រាប់បុគ្គលិកដែលបង្ហាញភស្តុតាងអាចទទួលយកបាននៃការចាក់វ៉ាក់សាំងពេញ

លេញដល់និយោជករបស់ខ្លួន ប៉ុន្តែនៅតែចាំបាច់ត្រូវពាក់ម៉ាស់ដដែល។
សម្រាប់បុគ្គលិកដែលបានទទួលវ៉ាក់សាំងពេញលេញដែលបានបង្ហាញភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញរបស់ពួកគេប្រឆាំងនឹងជំងឺ COVID-19 ហើយជ្រើសរើសមិនពាក់របាំងមុខ និយោជកគួរតែបង្កើត និងរក្សាកំណត់ត្រាជាលាយលក្ខណ៍អក្សរដែលឯកសារដែលបុគ្គលិកម្នាក់ៗបានបង្ហាញភស្តុតាងដែលអាចទទួលយកបានជាភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញ។
និយោជកមិនចាំបាច់រក្សាទុកច្បាប់ចម្លងនៃភស្តុតាងការចាក់វ៉ាក់សាំងពេញលេញដែលបានបង្ហាញនោះទេ។

- មនុស្សត្រូវបានចាត់ទុកថាបានចាក់វ៉ាក់សាំងពេញលេញបង្ការជំងឺ COVID-19 នៅ ≥2 សប្តាហ៍បន្ទាប់ពីពួកគេបានទទួលដូសទីពីរសម្រាប់ស៊េរីដែលមាន 2 ដូស (Pfizer-BioNTech ឬ Moderna) ឬ ≥2 សប្តាហ៍បន្ទាប់ពីពួកគេបានទទួលវ៉ាក់សាំងដែលមានមួយដូស (Johnson and Johnson [J&J]/Janssen)
- ឯកសារខាងក្រោមនេះគឺអាចទទួលបានដើម្បីឲ្យបុគ្គលិកបង្ហាញដល់និយោជករបស់ខ្លួនអំពីភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញបង្ការជំងឺ COVID-19៖ កាតចាក់វ៉ាក់សាំង (ដែលមានឈ្មោះរបស់បុគ្គលដែលបានចាក់វ៉ាក់សាំង ប្រភេទវ៉ាក់សាំងដែលបានចាក់ និងកាលបរិច្ឆេទដែលបានចាក់ដូសចុងក្រោយ) ឬរូបថតកាតចាក់វ៉ាក់សាំងជាឯកសារដាច់ដោយឡែក ឬរូបថតកាតវ៉ាក់សាំងរបស់អ្នកទទួលដែលបានរក្សាទុកក្នុងទូរសព្ទ ឬឧបករណ៍អេឡិចត្រូនិក ឬឯកសារនៃការចាក់វ៉ាក់សាំងពេញលេញពីអ្នកផ្តល់សេវាថែទាំសុខភាព (ដែលមានឈ្មោះបុគ្គលដែលបានចាក់វ៉ាក់សាំង និងបញ្ជាក់ថាបុគ្គលរូបនោះបានចាក់វ៉ាក់សាំងពេញលេញបង្ការជំងឺ COVID-19)។

- ❑ របាំងមុខនឹងត្រូវតែប្រើ សម្អាត និងធ្វើការសម្លាប់មេរោគ តាមការណែនាំរបស់ក្រុមហ៊ុនផលិតផលនេះ។
- ❑ ដើម្បីធ្វើឱ្យប្រាកដថាម៉ាស់ត្រូវបានពាក់យ៉ាងខ្ជាប់ខ្ជួននិងត្រឹមត្រូវ បុគ្គលិកត្រូវបានហាមឃាត់មិនឱ្យបរិភោគ ឬផឹក លើកលែងតែក្នុងអំឡុងពេលការសម្រាករបស់ពួកគេ នៅពេលដែលពួកគេអាចដោះម៉ាស់របស់ខ្លួននិងរក្សាគម្លាតរាងកាយពីអ្នកដទៃបានដោយសុវត្ថិភាព។ នៅគ្រប់ពេលវេលាទាំងអស់នៅពេលបរិភោគ ឬផឹក បុគ្គលិកត្រូវតែរក្សាគម្លាតយ៉ាងតិច 6 ហ្វីតពីអ្នកដទៃ។ នៅពេលបរិភោគ ឬផឹក វាជាការប្រសើរដែលត្រូវធ្វើដូច្នោះនៅខាងក្រៅអគារនិងឆ្ងាយពីអ្នកដទៃ។
- ❑ ចំនួនបុគ្គលិកដែលបម្រើអតិថិជនជាបុគ្គល ឬជាក្រុមនីមួយៗគួរតែត្រូវបានកំណត់ដោយស្របតាមបទបញ្ញត្តិស្តីពីប្រាក់ឈ្នួលនិងម៉ោងធ្វើការ។
- ❑ ចំនួនមនុស្សត្រូវតែកាត់បន្ថយ ហើយគម្លាតរវាងបុគ្គលិកគួរត្រូវបានបង្កើនដល់កម្រិតអតិបរមានៅក្នុងបន្ទប់ ឬកន្លែងនានាដែលបុគ្គលិកប្រើសម្រាប់បរិភោគអាហារនិង/ឬសម្រាក។ ចំណុចនេះត្រូវបានសម្រេចដោយ៖
    - បិទស្លាកកំណត់ចំនួនមនុស្សអតិបរមាដែលអនុញ្ញាតឱ្យមានការរក្សាគម្លាតយ៉ាងតិចប្រាំមួយហ្វីតរវាងបុគ្គលនៅក្នុងបន្ទប់ ឬកន្លែងដែលប្រើសម្រាប់ការសម្រាក
    - ឆ្លាស់ម៉ោងសម្រាក ឬម៉ោងបរិភោគអាហារ ដើម្បីកាត់បន្ថយចំនួនមនុស្សនៅក្នុងបន្ទប់ ឬទីកន្លែងដែលប្រើសម្រាប់ការបរិភោគអាហារ និងសម្រាក និង
    - ដាក់តុឃ្លាតពីគ្នាយ៉ាងតិច 8 ហ្វីត ដកកៅអី ឬបិទបង់ស្អិតលើកៅអីដើម្បីកាត់បន្ថយចំនួនមនុស្ស ដាក់គ្រឿងសង្ហារឹមលើកម្រាលឥដ្ឋ ដើម្បីធានាបាននូវការរក្សាគម្លាត និងរៀបចំកន្លែងអង្គុយតាមរបៀបមួយដែលកាត់បន្ថយការប៉ះពាល់ទល់មុខគ្នា។ ការប្រើប្រាស់របាំងខណ្ឌចែកត្រូវបានលើកទឹកចិត្តដើម្បីទប់ស្កាត់ការរីករាលដាលបន្ថែមទៀត ប៉ុន្តែមិនគួរចាត់ទុកថាជាវិធីជំនួសឱ្យការកាត់បន្ថយចំនួនមនុស្ស និងការរក្សាគម្លាតរាងកាយឡើយ។
- ❑ បុគ្គលិកត្រូវបានណែនាំអោយអនុវត្តអនាម័យដៃ រួមមានការលាងសម្អាតដៃឱ្យបានញឹកញាប់ ការប្រើប្រាស់ទឹកអនាម័យលាងសម្អាតដៃ និងការប្រើប្រាស់ស្រោមដៃឱ្យបានត្រឹមត្រូវ។
- ❑ បុគ្គលិកត្រូវបានអនុញ្ញាតឱ្យមានពេលសមស្របដើម្បីលាងដៃរបស់ខ្លួន។
- ❑ បុគ្គលិកត្រូវបានរម្លឹកឲ្យប្រើក្រដាសអនាម័យដើម្បីខ្ទប់មាត់នៅពេលក្អក និងកណ្តាស់។ ក្រដាសអនាម័យដែលបានប្រើរួចហើយគួរតែបោះចោលទៅក្នុងធុងសម្រាម ហើយលាងសម្អាតដៃភ្លាមៗជាមួយសាប៊ូ និងទឹកក្តៅយ៉ាងហោចណាស់ឱ្យបាន 20 វិនាទី។
- ❑ គ្រប់បុគ្គលិក អ្នកលក់ដូរ និងបុគ្គលិកដឹកជញ្ជូនត្រូវទទួលការណែនាំទាក់ទងនឹងការរក្សាគម្លាតរាងកាយ និងការប្រើប្រាស់ម៉ាស់នៅពេលមានអ្នកដទៃស្ថិតនៅជុំវិញ។
- ❑ បន្ទប់សម្រាក បន្ទប់ទឹក និងទីកន្លែងទូទៅផ្សេងទៀតត្រូវធ្វើការសម្លាប់មេរោគទៅតាមភាពញឹកញាប់ដូចខាងក្រោម ប៉ុន្តែមិនតិចជាងម្តងក្នុងមួយថ្ងៃ អំឡុងពេលប្រតិបត្តិការងារ ដោយយោងទៅតាមកាលវិភាគដូចខាងក្រោម៖
    - បន្ទប់សម្រាក ______________________________

- ○ បន្ទប់ទឹក ____________________
- ○ ផ្សេងទៀត ____________________

---

- ❑ សារធាតុសម្លាប់មេរោគ និងការផ្គត់ផ្គង់ដែលពាក់ព័ន្ធគឺមានសម្រាប់បុគ្គលិកទាំងអស់នៅទីតាំងដូចខាងក្រោម៖

---

- ❑ ទឹកអនាម័យលាងដៃដែលមានប្រសិទ្ធភាពប្រឆាំងជំងឺ COVID-19 គឺមានសម្រាប់បុគ្គលិកទាំងអស់នៅទីតាំងដូចខាងក្រោម៖

---

- ❑ ច្បាប់ចម្លងនៃពិធីការនេះត្រូវបានចែកចាយទៅបុគ្គលិកទាំងអស់។
- ❑ ជម្រើសផ្សេង—ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត៖

---

## B. វិធានការណ៍ដើម្បីធានាការរក្សាគម្លាតរាងកាយ

**ទីតាំងបរិភោគអាហារខាងក្នុងអគារ៖**

- ❑ ចំនួនអតិថិជននៅកន្លែងអង្គុយនៅខាងក្នុងអគារត្រូវបានកំណត់ត្រឹមតែមនុស្សចំនួន 25%នៃទីតាំងខាងក្នុងទាំងមូល ឬកំណត់ចំនួនអ្នកចូលជាអតិបរមាត្រឹមតែ100នាក់ មួយណាដែលតិចជាង។ នៅកន្លែងដែលអាចធ្វើទៅបាន ចំណតរថយន្តត្រូវតែរៀបចំឡើងវិញដើម្បីកំណត់ចំណុចនៃការ ប្រមូលផ្តុំគ្នា និងធានាបាននូវការនៅដាច់ពីគ្នាបានត្រឹមត្រូវ។
    - ○ ចំនួនអតិថិជនអតិបរមានៅទីតាំងអង្គុយខាងក្នុងអគារ កំណត់ត្រឹម៖ ____________________
- ❑ ដើម្បីធានាបាននូវការរក្សាគម្លាតរាងកាយពីគ្នាយ៉ាងហោចណាស់ 6 ហ្វីតរវាងអតិថិជនដែលអង្គុយនៅតុផ្សេងៗគ្នា តុទាំងអស់ត្រូវតែដាក់ឱ្យស្ថិតនៅចម្ងាយយ៉ាងតិចប្រាំមួយ (6)ហ្វីតពីគ្នា ដោយវាស់ពីកៅអីនៅនឹងតុខាងក្រោយដែលមានកៅអីនិងតុជាប់គ្នា ខណៈពេលអតិថិជនបានអង្គុយដែរ។ ក៏អនុញ្ញាតឱ្យមានផ្លូវកាត់បន្ទប់រវាងតុនិងតុដ៏ទៃទៀតដែលមានកៅអីដែលត្រូវរុញវាចេញនិងមានអតិថិជនអង្គុយនៅតុនោះ។ ប្រភេទរបាំងកញ្ចក់ ឬរបាំងផ្សេងទៀតមិនអាចជំនួសតម្រូវការទាមទារឱ្យរក្សាចន្លោះ រវាងតុនិងតុ និងរវាងអតិថិជនទាំងអស់បានទេ។ សូមមើល "គំរូនៃការរៀបចំកន្លែងអង្គុយដែលបានអនុម័តដោយបានអនុញ្ញាតតាមការកំណត់ចំនួនមនុស្ស" នៅផ្នែកខាងក្រោម។
- ❑ កន្លែងអង្គុយតាមតុនៅខាងក្នុងអគារត្រូវកំណត់ចំនួនមនុស្សមិនឱ្យលើសពី 6 នាក់ ពីក្រុមតែមួយ។ បុគ្គលទាំងអស់ដែលអង្គុយតាមតុនៅខាងក្នុងអគារត្រូវតែជាសមាជិកនៃគ្រួសារតែមួយ ហើយដូច្នោះមិនចាំបាច់អង្គុយចម្ងាយប្រាំមួយហ្វីតដាច់ពីគ្នាទេ។ មុនពេលអង្គុយ ម្ចាស់កម្មវិធីត្រូវបានដំណឹងដោយផ្ទាល់មាត់ទៅដល់ក្រុមនោះថាថាមនុស្សគ្រប់រូបដែល អង្គុយនៅតុរួមគ្នាត្រូវតែជាសមាជិកមកពីគ្រួសារតែមួយ។
- ❑ ប្រសិនបើសមាជិកទាំងអស់នៃក្រុមនេះបញ្ជាក់ និងបង្ហាញភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញប្រឆាំងនឹងជំងឺ COVID-19 មុនពេលអង្គុយពួកគេអាចនឹងអង្គុយជាមួយគ្នារហូតដល់ទៅប្រាំមួយ (6) នាក់ក្នុងមួយតុ និងដែលមកពីប្រាំមួយ(6)គ្រួសារផ្សេងគ្នា។ អតិថិជនដែលបានបញ្ជាក់ការចាក់វ៉ាក់សាំងពេញលេញត្រូវតែបង្ហាញទៅប្រតិបត្តិករនូវការផ្ទៀងផ្ទាត់ចាំបាច់ ដែលជាអត្តសញ្ញាណប័ណ្ណ និងភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញ ដូចជា ប័ណ្ណចាក់វ៉ាក់សាំង(ដែលរួមបញ្ចូលទាំងឈ្មោះអ្នកដែលបានចាក់វ៉ាក់សាំង ប្រភេទវ៉ាក់សាំងដែលបានផ្តល់ជូន និងកាលបរិច្ឆេទនៃដូសចុងក្រោយដែលនឹងត្រូវផ្តល់ជូន) ឬរូបថតនៃប័ណ្ណចាក់វ៉ាក់សាំងជាឯកសារដាច់ដោយឡែក ឬរូបថតនៃកាតវ៉ាក់សាំងរបស់អ្នកដែលត្រូវបានរក្សាទុកនៅក្នុងទូរស័ព្ទ ឬឧបករណ៍អេឡិចត្រូនិក ឬឯកសារនៃការចាក់វ៉ាក់សាំងប្រឆាំងនឹងCOVID-19 ពីមណ្ឌលថែទាំសុខភាព មុនពេលពួកគេអាចអង្គុយរួមគ្នាបាន.

**ទីតាំងបរិភោគអាហារខាងក្រៅអគារ៖**

- ❑ ចំនួនអតិថិជននៅទីកន្លែងអង្គុយខាងក្រៅគឺទាបល្មមដើម្បីធានាឱ្យបាននូវការរក្សាគម្លាតរាងកាយ។

តុនៅទីតាំងអង្គុយខាងក្រៅអគារត្រូវតែរៀបចំឱ្យមានចម្ងាយយ៉ាងតិចប្រាំមួយ (6) ហ្វីតរវាងតុមួយទៅតុមួយ ដោយវាស់ពីខ្នងកៅអីនៅតុមួយទៅខ្នងកៅអីនៅតុមួយទៀតដែលអតិថិជនអង្គុយ។ ប្រភេទរបាំងកញ្ចក់ ឬរបាំងផ្សេងទៀតមិនអាចជំនួសឲ្យគំលាតដែលចាំបាច់រវាងតុនិងតុ និងអតិថិជនឡើយ។ សូមមើល"ឧទាហរណ៍នៃការរៀបចំកន្លែងអង្គុយដែលបានអនុម័តដោយបានអនុញ្ញាតតាមការកំណត់ចំនួនមនុស្ស" ផ្នែកខាងក្រោម។

- ❑ ចំនួនអតិថិជនអតិបរមានៅទីតាំងអង្គុយខាងក្រៅអគារគឺកំណត់ត្រឹមៈ ________ ដូចដែលបានកំណត់ដោយចំនួនកៅអីសរុបដែលអាចប្រើបាន បន្ទាប់ពីតុត្រូវបានដាក់គម្លាតដូចបានពិពណ៌នាខាងលើ និងត្រូវមានចំនួនកៅអីអតិបរមាចំនួនប្រាំបី (8) នៅតាមតុនីមួយៗ។
- ❑ កន្លែងអង្គុយតាមតុនៅខាងក្រៅអគារត្រូវកំណត់ចំនួនមនុស្សមិនឱ្យលើសពីប្រាំបី (8) នាក់នៅក្នុងក្រុមតែមួយ។ មនុស្សទាំងអស់ដែលអង្គុយនៅតុខាងក្រៅអាចជាមនុស្សមកពីគ្រួសារផ្សេងដែលមិនលើសពីបីគ្រួសារឡើយ។ មុនពេលអង្គុយ ម្ចាស់កម្មវិធីត្រូវជូនដំណឹងដោយផ្ទាល់មាត់ទៅដល់ក្រុមនោះថាមនុស្សគ្រប់រូបដែលអង្គុយនៅតុរួមគ្នាមិនត្រូវមានសមាជិកដែលមកពីគ្រួសារលើសពី៣ឡើយ។
- ❑ ប្រសិនបើសមាជិកទាំងអស់នៃក្រុមបញ្ជាក់ និងបង្ហាញភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញប្រឆាំងនឹងជំងឺ COVID-19 ពួកគេអាចអង្គុយជាមួយគ្នាបានរហូតដល់ប្រាំបីនាក់ (8) នាក់ក្នុងមួយតុ និងរហូតដល់ទៅប្រាំបីគ្រួសារ (8) ផ្សេងគ្នា។ អតិថិជនដែលបានបញ្ជាក់ការចាក់វ៉ាក់សាំងពេញលេញត្រូវតែបង្ហាញទៅប្រតិបត្តិករនូវការផ្ទៀងផ្ទាត់ចាំបាច់ ដែលជាអត្តសញ្ញាណប័ណ្ណ និងភស្តុតាងនៃការចាក់វ៉ាក់សាំងពេញលេញដូចជាប័ណ្ណចាក់វ៉ាក់សាំង (ដែលរួមបញ្ចូលទាំងឈ្មោះអ្នកដែលបានចាក់វ៉ាក់សាំង ប្រភេទវ៉ាក់សាំងដែលបានផ្តល់ជូន និងកាលបរិច្ឆេទនៃដូសចុងក្រោយដែលនឹងត្រូវផ្តល់ជូន) ឬរូបថតនៃប័ណ្ណចាក់វ៉ាក់សាំងជាឯកសារដាច់ដោយឡែក ឬរូបថតនៃកាតវ៉ាក់សាំងរបស់អ្នកដែលត្រូវបានរក្សាទុកនៅក្នុងទូរស័ព្ទ ឬឧបករណ៍អេឡិចត្រូនិក ឬឯកសារនៃការចាក់វ៉ាក់សាំងប្រឆាំងនឹងCOVID-19 ពីអ្នកផ្តល់សេវាសុខភាព មុនពេលពួកគេអាចអង្គុយរួមគ្នាបាន។
- ❑ ប្រតិបត្តិករតាមអាជីវកម្មត្រូវត្រួតពិនិត្យកម្រិតចំនួនមនុស្សចូល និងចេញឱ្យបានតឹងរឹង និងបន្តបន្ទាប់គ្នាគ្រប់ច្រកចូល ដើម្បីអនុលោមតាមការកំណត់នៃទីតាំងដែលអាចផ្ទុកមនុស្សបាន។ ប្រតិបត្តិករដែលមិនត្រួតពិនិត្យគ្រប់គ្រាន់ ឬមិនបានត្រួតពិនិត្យ ឬហាក់ដូចជាមានចំនួនច្រើនលើសកំណត់តាមការណែនាំរបស់អាជ្ញាធរសុខភាពសាធារណៈ ទីតាំងអាជីវកម្មនោះអាចត្រូវបិទជាបណ្តោះអាសន្ន រហូតដល់បញ្ហាទាំងនេះត្រូវបានកែតម្រូវដែលកំណត់ដោយអាជ្ញាធរសុខភាពសាធារណៈនៅទីតាំងនោះតែម្តង។ ក្នុងករណីដែលអាចធ្វើទៅបាន ត្រូវរៀបចំច្រកចូលតែមួយដែលបានកំណត់យ៉ាងច្បាស់ និងច្រកចេញដាច់ដោយឡែកដើម្បីជួយរក្សាគម្លាត។
- ❑ ត្រៀមរៀបចំឱ្យអតិថិជនតម្រង់ជួរនៅខាងក្រៅ ខណៈដែលនៅតែអនុវត្តការរក្សាគម្លាតរាងកាយ រាប់បញ្ចូលទាំងការប្រើប្រាស់ស្លាកសញ្ញាតាមរយៈការប្រើរូបភាព។ បើសិនជាចាំបាច់ បុគ្គលិកម្នាក់ (ឬច្រើននាក់បើសិនជាមានច្រកចូលច្រើនជាងមួយ) ដែលពាក់ម៉ាស់អាចត្រូវបានដាក់ឱ្យប្រចាំការនៅជិតទ្វារ ប៉ុន្តែមានគម្លាតយ៉ាងតិច 6 ហ្វីតពីអតិថិជនដែលជិតបំផុត ដើម្បីតាមដានចំនួនអតិថិជន និងដើម្បីណែនាំអតិថិជនតម្រង់ជួរដោយឃ្លាតពីគ្នាប្រាំមួយហ្វីតនៅខាងក្រៅច្រកចូល បើសិនជាទីតាំងអាជីវកម្មបានឈានដល់ដែនកំណត់ចំនួនអតិថិជនរបស់ខ្លួន។
- ❑ អាជីវកម្មដែលប្រើប្រាស់ទីតាំងខាងក្រៅអគារត្រូវតែគោរពតាមលក្ខណៈវិនិច្ឆ័យរបស់រដ្ឋសម្រាប់ការកំណត់ល័ក្ខខ័ណ្ឌខាងក្រៅអគារដូចដែលបានបញ្ជាក់នៅក្នុងការណែនាំរបស់នាយកដ្ឋានសុខភាពរដ្ឋCalifornia អំពីការប្រើប្រាស់ [រចនាសម្ព័ន្ធបណ្តោះអាសន្នសម្រាប់ប្រតិបត្តិការអាជីវកម្មខាងក្រៅអគារ]()។ [រចនាសម្ព័ន្ធខាងក្រៅអគារដែលមិនបំពេញតាមលក្ខណៈវិនិច្ឆ័យរបស់រដ្ឋចំពោះការកំណត់ល័ក្ខខ័ណ្ឌខាងក្រៅត្រូវបានចាត់ចូលជាការការរៀបចំនៅខាងក្នុងអគារ ហើយកំណត់ត្រឹមតែ25%នៃទីតាំងទាំងមូលប៉ុណ្ណោះ។]()
- ❑ តុកាម៉ង់តាមបារដែលដាក់ក្នុងគោលបំណងដើម្បីរៀបចំ ឬបម្រើស្រាបៀរត្រូវតែដាក់ឱ្យនៅជិតតុសេវាកម្មភេសជ្ជៈ។
- ❑ ទូរទស្សន៍ ឬអេក្រង់ផ្សេងទៀតដែលមានទីតាំងនៅខាងក្នុង ឬខាងក្រៅអគារអាចត្រូវបានដាក់សម្រាប់ជូនអតិថិជនទស្សនាបាន។
- ❑ ការកម្សាន្តបន្តផ្ទាល់នៅខាងក្រៅត្រូវតែធ្វើតាមការកម្សាន្តសម្រាប់ព្រឹត្តិការណ៍ផ្សាយផ្ទាល់ខាងក្រៅអគារសម្រាប់ភោជនីយដ្ឋាន ឧបសម្ព័ន្ធ I។ ការកម្សាន្តបន្តផ្ទាល់នៅខាងក្នុងអគារមិនត្រូវបានអនុញ្ញាតទេ។

- ❑ អាជីវកម្មមិនអាចរៀបចំនៅខាងក្នុងអគារដូចជាពិធីទទួលភ្ញៀវ ពិធីជប់លៀង ឬព្រឹត្តិការណ៍ដែលមានការសម្របសម្រួល រៀបចំ ឬអញ្ជើញ ឬការជួបជុំគ្រប់ប្រភេទ។
- ❑ ក្នុងករណីដែលអាចធ្វើទៅបាន ត្រូវរៀបចំច្រកចូលតែមួយដែលបានកំណត់យ៉ាងច្បាស់ និងច្រកចេញដាច់ដោយឡែកដើម្បីជួយរក្សាគម្លាតរាងកាយ។
- ❑ វិធានការណ៍ដើម្បីធានាការរក្សាគម្លាតរាងកាយត្រូវតែគោរពតាមទីតាំងណាដែលអតិថិជន ឬនិយោជិកឈរតម្រង់ជួរ។ នេះរួមបញ្ចូលទាំងកន្លែងទូទាត់ការចំណាយនិងទីតាំងតាមបួក ជួរតុទូទាត់ការចំណាយ បន្ទប់ទឹក ជណ្តើរយន្ត កន្លែងឈរនិងកន្លែងរង់ចាំ កន្លែងរក្សានិងទទួលយកទំនិញ និងតំបន់ផ្សេងទៀតដែលអតិថិជនជួបជុំគ្នា។
  - ○ ការបិទបង់ស្អិត ឬគ្រឿងសម្គាល់ផ្សេងទៀតដែលមានគម្លាតយ៉ាងតិចប្រាំមួយហ្វីតពីគ្នានៅទីតាំងដែលសមាជិកនៃសាធារណជនអាចឈរតម្រង់ជួជាខ្សែ ឬឈរជាជួរ។
  - ○ គួររៀបចំឡើងនៃផ្លូវដើរ និងផ្លូវឆ្លងកាត់ដែលមានទិសផ្សេងៗសម្រាប់ចរាចរថ្មើរជើង ប្រសិនបើអាច ដើម្បីជៀសវាងការដើរឆ្លងកាត់គ្នារវាងបុគ្គលិកនិងអតិថិជនពីការដើកាត់គ្នាទៅវិញទៅមក។
  - ○ ប្រសិនបើអាចធ្វើបាន បុគ្គលិកដែលពាក់របាំងមុខ និងម៉ាស់គួរតែដាក់ឱ្យប្រចាំការនៅជិតទីតាំងនេះ ប៉ុន្តែយ៉ាងហោចណាស់រក្សាចម្ងាយ 6 ហ្វីតពីអតិថិជនដែលនៅជិតបំផុត ដើម្បីតាមដាននីតិវិធីនៃការរក្សាគម្លាតរាងកាយដូចដែលបានកំណត់ដើម្បីអនុវត្ត។
- ❑ សម្រាប់ទីតាំងដែលអាចប្រើបច្ចេកវិទ្យាដើម្បីជួយដោះស្រាយលើការអនុវត្តន៍ការកាត់បន្ថយនៃការប្រាស្រ័យទាក់ទងរវាងមនុស្សម្នាក់និងមនុស្សម្នាក់ទៀតគួរតែប្រើ ដូចជាការបញ្ជាទិញតាមទូរស័ព្ទដៃ និងប្រើបញ្ជីមុខម្ហូបតាមរយៈ ថេប្លេត (tablets) ផ្ញើសារនៅពេលភ្ញៀវចូលមកដល់ និងជម្រើសប្រព័ន្ធបង់ប្រាក់ដោយមិនបាច់ប៉ះផ្ទាល់។
- ❑ រៀបចំដំណើរការនៃការប្រាស្រ័យទាក់ទងរវាងអតិថិជន អ្នកដឹកជញ្ជូននិងបុគ្គលិកដើម្បីអនុញ្ញាតឱ្យមានការរក្សាគម្លាតរាងកាយ។
  - ○ គ្រប់ជាន់(floors)នៅខាងក្នុងនិងខាងក្រៅភោជនីយដ្ឋាននៅទីតាំងដែល អតិថិជន អ្នកលក់ដូរ បុគ្គលិកដឹកជញ្ជូន និងអ្នកទស្សនាដទៃទៀតអាចឈររង់ចាំត្រូវបិទកសម្គាល់ដើម្បីពង្រឹងគម្លាតរាងកាយ។
  - ○ ការប្រើវិធីឱ្យដំណើរការដោយគ្មានប៉ះពាល់ដោយផ្ទាល់សម្រាប់ការទទួលនិងការចែកចាយ ហើយក៏មានប្រព័ន្ធអេឡិចត្រូនិកផ្សេងទៀតសម្រាប់ធ្វើការប្រាស្រ័យទាក់ទងជាមួយភ្ញៀវត្រូវតែអនុវត្តនៅពេលដែលអាចធ្វើទៅបាន។
  - ○ ការប្រាស្រ័យទាក់ទងរវាងបុគ្គលិកនិងអតិថិជនត្រូវដាក់កំណត់ត្រឹមរយៈពេលជាអតិបរមា ៥ នាទីក្នុងមួយកន្លែង អនុវត្តតាមទីតាំងណាដែលអាចធ្វើបាន។
- ❑ កំណត់កម្រិតទំនាក់ទំនងរវាងបុគ្គលិក និងអតិថិជន។
  - ○ ដំឡើងរបាំងរាងកាយដូចជារនាំងបាំងឬរបាំងកញ្ចក់ នៅពេលចុះឈ្មោះ កន្លែងឈរ តុខាងមុខទទួលការកាម៉ង់ជាដើម ដែលការរក្សាគម្លាតរាងកាយប្រាំមួយហ្វីតគឺមានការលំបាក។
  - ○ កំណត់ចំនួនបុគ្គលិកដែលត្រូវបម្រើតាមតុជប់លៀងនីមួយៗ។
- ❑ កុំលើកទឹកចិត្តបុគ្គលិកនិងអតិថិជននៅជុំគ្នាតាមទីតាំងដែលមានចរាចរច្រើនដូចជាបន្ទប់ទឹក សាលធំ បរិវេណបារ កន្លែងទទួលការកក់ និងទីតាំងតាមប្លុកប្រើកាតឥណទាន ។ល។
- ❑ ពិធីការនៃការរក្សាគម្លាតរាងកាយគួរតែត្រូវបានប្រើនៅក្នុង ទីតាំងការិយាល័យ ផ្ទះបាយ បន្ទប់ដាក់ភេសជ្ជៈ ឬសម្ភារៈរបស់របរ បន្ទប់ម៉ាស៊ីនត្រជាក់ផ្ទុកទំនិញ ឬទីតាំងដែលមានបុគ្គលិកធ្វើចរាចរក្នុងកម្រិតដង់ស៊ីតេខ្ពស់។
  - ○ ពិចារណាថាមានការប៉ះពាល់ដោយចៃដន្យ ទោះយ៉ាងនេះក្តីគោលដៅគឺត្រូវដាក់កម្រិតឱ្យជួបគ្នាតិចជាង ១៥នាទី បើយកល្អត្រឹមតែ១០នាទី ហើយបុគ្គលិកត្រូវតែពាក់ម៉ាសការពារមុខជានិច្ច។

## C. វិធានការណ៍គ្រប់គ្រងការចម្លងមេរោគ

## មុនពេលបើកឱ្យដំណើរការ

- ❑ ប្រព័ន្ធ HVAC ត្រូវបានត្រួតពិនិត្យដោយអ្នកឯកទេស HVAC ក្នុងរយៈពេល 30 ថ្ងៃនៃការបើកឡើងវិញ ហើយប្រព័ន្ធនេះមានសភាពល្អ ឬអាចដំណើរការបាន ដល់កម្រិតអតិបរមាដែលអាចធ្វើទៅបាន ហើយប្រព័ន្ធខ្យល់ត្រូវតែបន្ថែម។

ប្រព័ន្ធខ្យល់ដែលមានប្រសិទ្ធិភាពគឺជាវិធីមួយក្នុងចំណោមវិធីសំខាន់បំផុតដើម្បីគ្រប់គ្រងការសាយភាយនៃតំណក់ទឹកតូចៗ។

- ពិចារណាតំឡើងម៉ាស៊ីនសម្អាតខ្យល់ដែលមានប្រសិទ្ធិភាពខ្ពស់ដែលអាចចល័តបាន ធ្វើឱ្យប្រសើរឡើងនូវតម្រងខ្យល់របស់អគារឱ្យមានប្រសិទ្ធិភាពខ្ពស់បំផុតតាមដែលអាចធ្វើបាន និងធ្វើការកែប្រែផ្សេងទៀតដើម្បីបង្កើនបរិមាណខ្យល់ខាងក្រៅនិងខ្យល់ចេញចូលនៅគ្រប់ទីតាំងធ្វើការ។
- សូមមើលការណែនាំសុខភាពសាធារណៈរដ្ឋកាលីហ្វ័រញ៉ាអំពី ប្រព័ន្ធខ្យល់ចេញចូលតាមតម្រង និងគុណភាពខ្យល់នៅក្នុងបរិយាកាសខាងក្នុង សម្រាប់ព័ត៌មានលម្អិត។
- សូមចំណាំ៖ ប្រព័ន្ធខ្យល់និងការកែលម្អគុណភាពខ្យល់ខាងក្នុងគឺត្រូវតែបន្ថែមទៀត ដោយមិនត្រូវជំនួសវានូវការការពារចាំបាច់រួមមានការពាក់របាំងគ្របមុខ (លើកលែងតែបរិយាកាសជាក់លាក់ដែលមានហានិភ័យខ្ពស់ដែលទាមទារឱ្យមានការការពារផ្លូវដង្ហើមត្រឹមត្រូវ) រក្សាគម្លាតយ៉ាងតិច 6ហ្វីតរវាងមនុស្សនិងមនុស្ស លាងដៃឱ្យបានញឹកញាប់ និងកំណត់សកម្មភាពដែលប្រមូលផ្តុំមនុស្សមកពីគ្រួសារផ្សេងៗគ្នា។

- ☐ អាជីវកម្មដែលមិនបានដំណើរការ សូមបង្ហូរទាំងទឹកក្តៅនិងត្រជាក់ឱ្យបានរយៈពេល ៥ នាទីមុនពេលបើកឡើងវិញដើម្បីផ្លាស់ប្តូរទឹកដែលមាននៅក្នុងបំពង់បង្ហូរដើម្បីបានទឹកដែលស្អាតនិងមានសុវត្ថិភាព។
- ☐ តាមហាងអាជីវកម្មត្រូវតែធ្វើការសម្អាត និងសម្លាប់មេរោគឱ្យបានហ្មត់ចត់ (ប្រើប្រាស់ផលិតផលដែលត្រូវបានអនុញ្ញាតសម្រាប់ប្រឆាំងមេរោគ COVID-19) ជាពិសេសប្រសិនបើទីតាំងនោះត្រូវបានបិទក្នុងពេលកន្លងមក។
  - ជ្រើសរើសប្រើសេវាកម្មពីក្រុមហ៊ុនសម្អាតដែលជាភាគីទីបីដើម្បីជួយដល់ការសម្អាតតាមតែការចាំបាច់។
- ☐ ទីតាំងមួយចំនួនដូចជាកន្លែងអង្គុយ កន្លែងឈរ និងទីតាំងរៀបចំភេសជ្ជៈត្រូវតែបំពាក់ផលិតផលអនាម័យឱ្យបានត្រឹមត្រូវ រួមទាំងទឹកអនាម័យលាងសម្អាតដៃ និងក្រដាសជូតសម្លាប់មេរោគសម្រាប់បុគ្គលិកទាំងអស់ដែលប្រើប្រាស់ជំនួយជូនដល់អតិថិជនដោយផ្ទាល់។
  - ធានាឱ្យបានថាគ្រប់ទីកន្លែងត្រូវមានសម្ភារៈអនាម័យសម្រាប់ធ្វើប្រតិបត្តិការ និងមាននៅក្នុងស្តុកទុកគ្រប់ពេលដោយមានសាប៊ូ ក្រដាស និងទឹកអនាម័យលាងដៃ នៅពេលចាំបាច់។
  - សូមណែនាំឱ្យតំឡើងម៉ាស៊ីនលាងសម្អាតដៃដែលមិនប៉ះដោយផ្ទាល់សម្រាប់លាងសម្អាតដៃ ម៉ាស៊ីនសាប៊ូ ក្រដាស និងឧបករណ៍ដាក់សម្រាម។
- ☐ ទីតាំងទម្លាក់ទំនិញត្រូវបានកំណត់ដើម្បីទទួលបានការចែកចាយដែលនៅទីតាំងមិនមានចរាចរច្រើន។ ទំនាក់ទំនងពីមនុស្សម្នាក់ទៅមនុស្សម្នាក់សម្រាប់ការដឹកជញ្ជូនទំនិញត្រូវតែលុបចោលនៅពេលណាដែលអាចធ្វើទៅបាន។

## ការពិចារណាចំពោះសុវត្ថិភាពចំណីអាហារ

- ☐ រាល់ការអនុវត្តសុវត្ថិភាពចំណីអាហារដែលបានចែងនៅក្នុងក្រមអាហារលក់រាយរបស់រដ្ឋCalifornia (CRFC) ត្រូវតែអនុវត្តតាមនិងបន្តការអនុវត្តនេះ។
  - ត្រូវរក្សាទុកអាហារក្តៅ (កម្តៅ 135°F ឬខ្ពស់ជាងនេះ) និងអាហារត្រជាក់ (41°F ឬខាងក្រោមនេះ)។
  - ចម្អិនអាហារយ៉ាងហ្មត់ចត់តាមតម្រូវការដែលមាននៅក្នុង CRFC។
  - ឧបករណ៍និងសម្ភារៈត្រូវតែស្អាតនិងមានអនាម័យ ដូចដែលមានចែងនៅក្នុងCRFC។
  - ប្រកាន់ខ្ជាប់នូវការអនុវត្តសុខភាព និងអនាម័យរបស់បុគ្គលិក៖ កុំធ្វើការនៅពេលឈឺ លាងដៃញឹកញាប់ ប្រើស្រោមដៃដូចដែលជាតម្រូវការទាមទាររបស់ CRFC។
  - ធានាថារាល់គ្រឿងផ្សំអាហារ និងចំណីអាហារគឺយកមកពីប្រភពអាហារដែលទទួលបានការអនុម័តយល់ព្រម។
  - បុគ្គលិកផ្នែករៀបចំអាហារមិនត្រូវបានលើកទឹកចិត្តឱ្យផ្លាស់ប្តូរ ឬចូលទីតាំងការងាររបស់អ្នកដទៃតាមវេនផ្សេងៗឡើយ។
- ☐ ម៉ាស៊ីនដែលផ្តល់សេវាកម្មដោយខ្លួនឯង ដូចជាម៉ាស៊ីនចាក់ទឹកសូដាត្រូវចាត់ចែងដោយបុគ្គលិកម្ហូបអាហារ ហើយផ្ទៃដែលមានការប៉ះពាល់ត្រូវតែសម្អាត និងមានអនាម័យជារៀងរាល់ម៉ោង។
- ☐ ទីតាំងដែលអតិថិជនអាចប្រមូលផ្តុំ ឬប៉ះពាល់អាហារ ឬរបស់របរប្រើប្រាស់ផ្សេងៗ ដែលអតិថិជនដទៃទៀតអាចនឹងប្រើប្រាស់ត្រូវតែបិទ។

របស់របរទាំងនេះដែលត្រូវប្រើសម្រាប់ផ្តល់ជូនទៅអតិថិជនជាលក្ខណៈបុគ្គល ហើយអាចបោះចោល ឬសម្អាត និងត្រូវសម្លាប់មេរោគបន្ទាប់ពីការប្រើប្រាស់នីមួយៗតាមការសមស្រប។ នេះរួមបញ្ចូលប៉ុន្តែមិនកម្រិតត្រឹមនេះទេ៖

- ទីតាំងបម្រើសេវាខ្លួនឯងដោយមាន គ្រឿងថែម សមនិងស្លាបព្រា ក្រណាត់ក្រាល គម្រប និងទុយោបឺត ចានជ័រឬប្លាស្ទិចសម្រាប់ខ្ចប់។ល។
- តំបន់អាហារដែលផ្តល់សេវាកម្មដោយខ្លួនឯងដូចជាតុម្ហូបបន្លែ (សាឡាត់) ឬអាហារប៊ូហ្វេ រួមទាំងម្ហូបអាហារសម្រាប់ភ្លក្ស។
- ក្រោយពីទទួលទានអាហារ មានស្ករគ្រាប់ អាហារសម្រន់តិចតួច ឬឈើចាក់ធ្មេញសម្រាប់អតិថិជន។ របស់ទាំងនេះត្រូវផ្តល់ជូនភ្ជាប់ជាមួយមូលប្បទានប័ត្រ ឬផ្តល់ជូនតាមការស្នើសុំ។

- ❑ បុគ្គលិកដែលបានកំណត់ទទួលខុសត្រូវបម្រើអាហារត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចវេចខ្ចប់សម្ភារស្លាបព្រា សម ឬកាំបិត មុនពេលប្រគល់ជូនទៅអតិថិជន ជៀសជាងមានបុគ្គលិកច្រើននាក់ដែលត្រូវទទួលខុសត្រូវលើសម្ភារៈស្លាបព្រា/សមឬកាំបិតដោយមិនបានខ្ចប់ទុកមុនសម្រាប់ការប្រើប្រាស់របស់អតិថិជន។
- ❑ ការបំពេញភេសជ្ជៈនៅតាមតុ ឬពីធុងទូទៅ (ឧទាហរណ៍ កាដុងធំមានដៃចុច កែវធំៗដាក់ទឹកឬស្រា ដបដាក់ស្រា ដបផ្សេងៗទៀត) មិនត្រូវបានអនុញ្ញាតឱ្យប្រើនោះទេ។ កែវស្រាថ្លាស្អាតត្រូវប្រគល់ជូនដល់អតិថិជនដើម្បីយកទៅបំពេញឬថែម។

## ការពិចារណាលើទីតាំង

- ❑ បន្ទប់ទឹកត្រូវបានត្រួតពិនិត្យជាប្រចាំ និងសម្អាត ហើយសម្លាប់មេរោគយ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ ឬញឹកញាប់បំផុតតាមការចាំបាច់ ដោយប្រើថ្នាំសម្លាប់មេរោគEPA។
- ❑ បុគ្គលិកផ្នែករៀបចំអាហារតាមវេនម្នាក់ ត្រូវចាត់តាំងឱ្យត្រួតពិនិត្យ និងពង្រឹងលើនីតិវិធីនៃការលាងសម្អាត និងសម្លាប់មេរោគបន្ថែម តាមតម្រូវការចាំបាច់។
- ❑ ផែនការសម្អាតនិងសម្លាប់មេរោគសម្រាប់ផ្ទៃដែលមានការប៉ះច្រើន និងទីតាំងដែលមានការចេញ-ចូលត្រូវបានរៀបចំបន្ថែមទៀត ហើយត្រូវតែអនុវត្តតាមការណែនាំ។
  - ទីកន្លែងទូទៅ និងទីកន្លែងដែលមានផ្ទៃត្រូវបានប៉ះជាញឹកញាប់ដោយពាក់ព័ន្ធនឹងការទទួល និងការទូទាត់របស់អតិថិជន (ឧទាហរណ៍ ដៃទ្វារ ឬដៃកាន់ ម៉ាស៊ីនកាតឥណទាន)ត្រូវតែធ្វើការសម្លាប់មេរោគយ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ ក្នុងអំឡុងពេលម៉ោងធ្វើការ ដោយប្រើថ្នាំសំលាប់មេរោគដែលត្រូវបានអនុម័តដោយEPA។
- ❑ បង្កើនការសម្អាត និងការសម្លាប់មេរោគសម្រាប់ផ្ទៃដែលស្ថិតនៅក្នុងតំបន់ដែលមានចរាចរណ៍ខ្ពស់ ឬសម្រាប់ផ្ទៃដែលត្រូវបានប៉ះពាល់ជាមួយបុគ្គលដែលមិនពាក់ម៉ាស់។ ទីកន្លែងអាជីវកម្មត្រូវតែធ្វើការសម្អាត និងសម្លាប់មេរោគឱ្យបានហ្មត់ចត់ (ប្រើប្រាស់ផលិតផលដែលត្រូវបាន អនុញ្ញាតសម្រាប់ប្រឆាំងមេរោគ COVID-19) ជារៀងរាល់ពេលយប់។ កំណត់ហេតុត្រូវបានរក្សាទុកដើម្បីត្រួតពិនិត្យសម្រាប់ការបំពេញនៅតាមកន្លែងដែលអាចធ្វើទៅបាន។
- ❑ កាសស្តាប់ដាក់ត្រចៀក និងឧបករណ៍ផ្សេងទៀតមិនត្រូវចែករំលែករវាងបុគ្គលិកទេលើកលែងតែឧបករណ៍នោះត្រូវបានធ្វើការសម្លាប់មេរោគឱ្យបានត្រឹមត្រូវបន្ទាប់ពីការប្រើប្រាស់ម្តងៗ។ ពិគ្រោះជាមួយអ្នកផលិតឧបករណ៍ដើម្បីកំណត់អំពីវិធីលាងចានបានត្រឹមត្រូវ។
- ❑ បុគ្គលិកលាងចានត្រូវផ្តល់ឱ្យនូវឧបករណ៍ដើម្បីការពារភ្នែក ច្រមុះ និងមាត់ ដើម្បីការពារការចម្លងរោគដោយសារតែមានទឹកសាចមកលើ ដោយតម្រូវឱ្យប្រើការឧបករណ៍ រួមមានម៉ាស់ការពារ វ៉ែនតាការពារ និង/ឬរបាំងមុខ។ បុគ្គលិកលាងចានត្រូវផ្តល់ឱ្យអៀមពាក់លើខ្លួន ហើយតម្រូវឱ្យផ្លាស់ប្តូរជាញឹកញាប់។ ឧបករណ៍ការពារដែលអាចប្រើឡើងវិញបាន មានដូចជា របាំងមុខ និងវ៉ែនតាតែត្រូវធ្វើការសម្លាប់មេរោគឱ្យបានត្រឹមត្រូវរាល់ការប្រើប្រាស់។
- ❑ ទឹកអនាម័យលាងសម្អាតដៃ និងធុងសម្រាមអាចប្រើប្រាស់បានសម្រាប់សាធារណជនដែលនៅ ឬនៅជិតច្រកចូលនៃទីតាំងបម្រើសេវាភេសជ្ជៈនៅខាងក្រៅអគារនោះតែម្តង។

## តំបន់អតិថិជន/តំបន់សេវាកម្ម

- ☐ អតិថិជនត្រូវបានណែនាំថាពួកគេត្រូវតែពាក់ម៉ាស់នៅពេលណាដែលពួកគេពិសាភេសជ្ជៈ រួមបញ្ចូលទាំងការចូលទៅកន្លែងអង្គុយនៅខាងក្នុងនិង ឬខាងក្រៅ នៅពេលដើរគ្រប់ទីកន្លែងនៅក្នុងទីតាំងកន្លែងអង្គុយនៅខាងក្នុងនិង ឬខាងក្រៅ និងពេលប្រើបន្ទប់ទឹក ។ នេះអនុវត្តទៅលើមនុស្សធំទាំងអស់ និងកុមារដែលមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ។ មានតែបុគ្គលដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្រថាពួកគេដែលមិនចាំបាច់ពាក់ម៉ាស់ តែត្រូវពាក់របាំងគ្របមុខដែលមានក្រណាត់នៅលើគែមខាងក្រោមដោយអនុលោមតាមការណែនាំរបស់រដ្ឋ ខណៈណាដែលស្ថានភាពរបស់ពួកគេអាចធ្វើទៅបាន។ ក្រណាត់ដែលមានទ្រង់ទ្រាយពាក់បិទជិតនៅក្រោមចង្កាត្រូវបានលើកទឹកចិត្តឱ្យប្រើ។ ម៉ាស់ដែលមានវ៉ាល់តែមួយផ្លូវ មិនត្រូវប្រើទេ។ ដើម្បីគាំទ្រសុវត្ថិភាពរបស់បុគ្គលិក និងភ្ញៀវផ្សេងទៀត គួរផ្តល់ម៉ាស់ដល់ភ្ញៀវដែលចូលមកក្នុងបរិវេណដោយមិនមានវា។
  - អតិថិជនអាចដោះម៉ាស់ចេញបានតែពេលអង្គុយនៅតុនិងទទួលទានអាហារ ឬភេសជ្ជៈតែប៉ុណ្ណោះ។
  - អតិថិជនត្រូវតែអង្គុយនៅពេលទទួលទានអាហារ ឬភេសជ្ជៈអ្វីក៏ដោយ។ អតិថិជនមិនអាចទទួលទានភេសជ្ជៈដោយដើរជុំវិញទីតាំងបានទេ។
  - អតិថិជនដែលបដិសេធមិនពាក់ម៉ាស់អាចត្រូវបានបដិសេធមិនមានផ្តល់សេវាកម្មហើយស្នើសុំឱ្យចាកចេញពីទីតាំងនេះ។
- ☐ សេចក្តីណែនាំសម្រាប់អតិថិជន។ គ្រប់អាជីវកម្មទាំងអស់ត្រូវតែដាក់សញ្ញាឬផ្លាក (មិនតូចជាង 3 x 5 អ៊ីញ) នៅលើតុដោយយ៉ាងហោចណាស់មានការណែនាំដូចខាងក្រោម ឬស្រដៀងគ្នានេះ បន្ទាប់ពីការលាងសម្អាតតុនីមួយៗរវាងក្រុមអតិថិជន៖

  "សូមចូលរួមជួយយើងខ្ញុំដើម្បីរក្សាការបើកដំណើរការអាជីវកម្មរបស់យើងខ្ញុំ ការពារបុគ្គលិករបស់យើងខ្ញុំ និងការពារអតិថិជនដោយធ្វើតាមគោលការណ៍ណែនាំសាមញ្ញរបស់យើង៖
  - ពាក់ម៉ាស់របស់អ្នករហូតដល់អ្នកទទួលបានភេសជ្ជៈ ហើយបន្ទាប់ពីបានទទួលទានភេសជ្ជៈរួចរាល់។
  - ពាក់ម៉ាស់របស់អ្នកនៅពេលណាបុគ្គលិកបម្រើសេវាមកដល់តុរបស់អ្នក។
  - ពាក់ម៉ាស់របស់អ្នកនៅពេលណាដែលអ្នកចាកចេញពីតុ។
  - លាងសម្អាតដៃឬប្រើទឹកលាងដៃ។

  សូមអរគុណចំពោះការជួយការពារសុខភាពបុគ្គលិក និងអតិថិជនរបស់យើងខ្ញុំ!"

  តារាងក្រាហ្វិចគំរូនៃសុវត្ថិភាពអំពីជំងឺ COVID-19 អាចរកបានតាមរយៈតំណនេះ៖ http://publichealth.lacounty.gov/media/Coronavirus/docs/food/TableTop.pdf។ ជម្រើសផ្សេងទៀត ដូចជាផ្លាកសញ្ញា ផ្ទាំងឌីជីថល ក្នុងចំណោមឧបករណ៍ផ្សេងទៀត អាចត្រូវបានប្រើនៅក្នុងទីតាំងបម្រើសេវាកម្មភេសជ្ជៈដើម្បីជូនដំណឹងនិងរម្លឹកដល់អតិថិជនអំពីការណែនាំទាំងនេះនៅពេលពួកគេអង្គុយ និងអំឡុងពេលវេលាពួកគេកម្សាន្តនៅទីតាំងអាជីវកម្មនេះ។
- ☐ កម្រិតសំឡេងតន្ត្រី ឬទូរទស្សន៍ត្រូវតែបន្ថយដើម្បីធានាថាបុគ្គលិកបម្រើការអាចស្តាប់ការបញ្ជាទិញរបស់អតិថិជនដោយមិនចាំបាច់អោនទៅលើអតិថិជន។
- ☐ ការត្រួតពិនិត្យការចូល ត្រូវបានធ្វើឡើងមុនពេលអតិថិជនអាចចូលក្នុងកន្លែងនោះ។ ការត្រួតពិនិត្យនេះត្រូវតែឆែកមើលលើស្ថានភាពពាក់ព័ន្ធនឹងការក្អក ការដកដង្ហើមខ្លី ការពិបាកដកដង្ហើម និងគ្រុនក្តៅឬញាក់ញ័រ និងថាតើបុគ្គលនោះកំពុងស្ថិតក្រោមសេចក្តីបង្គាប់ឱ្យនៅដាច់ដោយឡែក ឬការធ្វើចត្តាឡីស័ក (ដាក់ឱ្យដាច់ពីគេ)នាពេលថ្មីៗនេះ។ ការត្រួតពិនិត្យទាំងនេះអាចធ្វើទៅបានដោយផ្ទាល់ ឬតាមរយៈវិធីសាស្ត្រជំនួសដូចជាការត្រួតពិនិត្យតាមអនឡាញដោយប្រើប្រព័ន្ធប្រតិបត្តិ ឬតាមរយៈផ្លាកសញ្ញាដែលមានបិទនៅច្រកចូលនៃបរិវេណអាជីវកម្មដែលបញ្ជាក់ថាភ្ញៀវណាដែលមានរោគសញ្ញាទាំងនេះមិនត្រូវចូលក្នុងបរិវេណឡើយ។
  - ការត្រួតពិនិត្យទទួលលទ្ធផលអវិជ្ជមាន (មិនមានបញ្ហា)។ ប្រសិនបើបុគ្គលនោះមិនមានរោគសញ្ញា និងគ្មានប៉ះពាល់ជាមួយករណីជំងឺ COVID-19 ដែលបានរកឃើញក្នុងរយៈពេល 10 ថ្ងៃចុងក្រោយនេះទេ ពួកគេគឺមិនមានបញ្ហា ហើយអាចចូលទៅទីតាំងបានសម្រាប់ថ្ងៃនោះ។
  - ការត្រួតពិនិត្យទទួលលទ្ធផលវិជ្ជមាន (មានបញ្ហា)៖
    - ប្រសិនបើបុគ្គលនោះបានទាក់ទងជាមួយករណីជំងឺ COVID-19 ដែលបានរកឃើញក្នុងរយៈពេល 10 ថ្ងៃចុងក្រោយ ឬថ្មីៗនេះស្ថិតនៅក្រោមការដាក់ឱ្យនៅដាច់ពីគេ ពួកគេមិនអាចចូលទីតាំងនេះបានទេ ហើយត្រូវបញ្ជូនទៅផ្ទះភ្លាមៗដើម្បីដាក់ឱ្យនៅដាច់ពីគេនៅក្នុងផ្ទះ។ ផ្តល់ជូនពួកគេ

នូវការណែនាំនៃការធ្វើចត្តាឡីស័ក (ដាក់ឱ្យនៅដាច់ពីគេ) តាមតំណភ្ជាប់ ph.lacounty.gov/covidquarantine។

- ប្រសិនបើមនុស្សនោះបង្ហាញរោគសញ្ញាដែលត្រូវបានកំណត់សម្គាល់ដូចខាងលើ ឬកំពុងស្ថិតនៅក្រោមការបញ្ជាឱ្យធ្វើការដាក់ឱ្យនៅដាច់ដោយឡែក គេមិនអាចចូលបានទេហើយ ត្រូវតែបញ្ជូនទៅផ្ទះវិញភ្លាមៗដើម្បីធ្វើការនៅដាច់ដោយឡែកនៅផ្ទះ។ ផ្តល់ជូនពួកគេនូវការណែនាំនៃការដាក់ឱ្យនៅដាច់ពីគេតាមតំណភ្ជាប់ ph.lacounty.gov/covidisolation។

- ❑ បុគ្គលិកបម្រើ បុគ្គលិករៀបចំតុ និងបុគ្គលិកផ្សេងទៀតដែលប្រមូលរបស់របរដែលប្រើដោយអតិថិជន (ដូចជាពែង កខ្វក់ ចាន កន្សែង ជាដើម) ឬថង់យួរសម្រាប់ដាក់សម្រាម ត្រូវលាងដៃរបស់ខ្លួនបន្ទាប់ពីបញ្ចប់កិច្ចការនេះ ហើយត្រូវបានផ្តល់ឱ្យប្រើអៀមពាក់លើខ្លួនដែលពួកគេត្រូវផ្លាស់ប្តូរឱ្យបានញឹកញាប់។
- ❑ បញ្ជីមុខម្ហូបដែលអាចប្រើជាច្រើនដងត្រូវធ្វើការសម្អាតនិងសម្លាប់មេរោគរវាងអតិថិជនមួយទៅអតិថិជនមួយទៀត។ ជម្រើសផ្សេងទៀតដូចជាបញ្ជីមុខម្ហូបប្រើលើផ្ទាំងក្តា បញ្ជីមុខម្ហូបលើទូរស័ព្ទឌីជីថល ឬបញ្ជីមុខម្ហូបទូរស័ព្ទចល័តដែលអាចទាញយកមកមើលបានគួរតែត្រូវបានពិចារណាក្នុងការប្រើប្រាស់។
- ❑ កន្លែងអង្គុយរបស់អតិថិជន ត្រូវធ្វើការសម្អាត និងរក្សាអនាម័យបន្ទាប់ពីប្រើប្រាស់ម្តងៗ។ កន្លែងអង្គុយ តុ និងរបស់របរផ្សេងៗទៀតនៅលើតុត្រូវតែប្រើប្រាស់សម្រាប់តែមួយដង ឬត្រូវសម្អាត/រក្សាអនាម័យរវាងអតិថិជនមួយទៅអតិថិជនមួយទៀត។ តុនីមួយៗដែលមានកម្រាលត្រូវតែផ្លាស់ប្តូរ ឬប្រើឧបករណ៍បាញ់សម្លាប់មេរោគនៅលើផ្ទៃលាងសម្អាតរវាងភ្ញៀវមួយទៅភ្ញៀវមួយទៀត។
- ❑ ប្រអប់សម្រាប់ខ្ចប់អាហារត្រូវត្រៀមទុកសម្រាប់អតិថិជន ដើម្បីអាចយកមកប្រើបាននៅពេលមានការស្នើសុំ។
- ❑ ប្រតិបត្តិការទូទាត់ការចំណាយដោយគ្មានប្រើសាច់ប្រាក់ត្រូវបានលើកទឹកចិត្ត។ ប្រសិនបើមានហេតុផលសមស្រប ចំពោះទីតាំងអាជីវកម្មនោះ អតិថិជនអាចប្រើដោយការឆូតកាតឥណទាន/ឥណពន្ធផ្ទាល់ខ្លួន ហើយឧបករណ៍សម្រាប់ឆូតកាតនោះត្រូវតែសម្អាតអនាម័យយ៉ាងពេញលេញរាល់ការប្រើប្រាស់របស់ភ្ញៀវម្នាក់ៗ។
- ❑ ក្រណាត់កខ្វក់ដែលបានប្រើនៅតុអតិថិជនដូចជាកម្រាលតុនិងកន្សែងគួរត្រូវបានយកចេញបន្ទាប់ពីអតិថិជនម្នាក់ៗប្រើប្រាស់ ។ បុគ្គលិកគួរតែពាក់ស្រោមដៃនៅពេលត្រូវរៀបចំតុដែលមានក្រណាត់កខ្វក់។
- ❑ ជម្រើសផ្សេង - ពិពណ៌នាអំពីវិធានការណ៍ផ្សេងទៀត (ឧទាហរណ៍ ការផ្តល់ម៉ោងធ្វើការសម្រាប់តែជនចាស់ជរា ការលើកទឹកចិត្តឱ្យមានការចូលមកហាងនៅពេលមិនសូវរវល់ខ្លាំង)៖

______________________________________________________________________

## D. វិធានការណ៍ដែលប្រាស្រ័យទាក់ទងទៅសាធារណជន

- ❑ ច្បាប់ចម្លងនៃពិធីការនេះ ឬវិញ្ញាបនបត្រអនុលោមតាមសុវត្ថិភាពនៃជំងឺCOVID-19 របស់ខោនធី Los Angeles ត្រូវបានបិទផ្សាយនៅគ្រប់ច្រកចូលសាធារណៈទាំងអស់មកក្នុងអគារ។ សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីបំពេញតាមកម្មវិធីបញ្ជាក់វិញ្ញាបនបត្រដោយខ្លួនឯង ដោយអនុលោមតាមសុវត្ថិភាពជំងឺ COVID-19 សូមចូលទៅកាន់គេហទំព័រ http://publichealth.lacounty.gov/eh/covid19cert.htm។ ទីកន្លែងត្រូវតែរក្សាទុកច្បាប់ចម្លងនៃពិធីការនៅទីតាំងការងារដើម្បីកែសម្រួល តាមការស្នើសុំ។
- ❑ ស្លាកសញ្ញាត្រូវបានបិទផ្សាយនៅតាមច្រកចូលទាំងអស់មកកាន់ទីតាំងដើម្បីរំឭកអតិថិជនឱ្យរក្សាគម្លាតរាងកាយ ៦ហ្វីត អនុវត្តការលាងដៃឬការប្រើប្រាស់ទឹកអនាម័យលាងដៃរាល់ការចូលមកដល់ភោជនីយដ្ឋាន ត្រូវពាក់ម៉ាស់ពេលអ្នកមិនទទួលទានអាហារ ឬភេសជ្ជៈ ហើយត្រូវស្នាក់នៅតែផ្ទះ ប្រសិនបើពួកគេឈឺ ឬមានរោគសញ្ញាដែលស្រដៀងទៅនឹងជំងឺ COVID-19។ សូមមើលការណែនាំតាមគេហទំព័រ ខោនធី DPH COVID-19 សម្រាប់ព័ត៌មានបន្ថែម និងឧទាហរណ៍នៃផ្លាកសញ្ញាដែលអាចយកទៅប្រើតាមអាជីវកម្មផ្សេងៗ។
- ❑ គ្រប់ហាងអាជីវកម្មអនឡាញ (គេហទំព័រ បណ្តាញសង្គម ។ល។)ត្រូវផ្តល់ព័ត៌មានច្បាស់លាស់អំពីម៉ោងដំណើរការតាមអាជីវកម្ម ការតម្រូវឱ្យប្រើម៉ាស់ គោលការណ៍ផ្សេងៗដែលទាក់ទង ការកាប់ង់មុនពេល ការកក់ទុកជាមុន ការទូទាត់ប្រាក់ទុកជាមុន ការមកទទួលអាហារ និង/ឬ ការដឹកជញ្ជូន និងបញ្ហាដែលពាក់ព័ន្ធផ្សេងៗទៀត។

## E. វិធានការណ៍ដែលធានាបាននូវការប្រើប្រាស់សេវាកម្មសំខាន់ៗដោយស្មើភាព (សមធម៌)

- ❑ សេវាកម្មដែលចាំបាច់ខ្លាំងសម្រាប់អតិថិជនត្រូវបានផ្តល់អាទិភាព។

- ❑ ប្រតិបត្តិការ ឬសេវាកម្មដែលអាចបម្រើពីចម្ងាយ ត្រូវបានប្តូរទៅអនឡាញ។
- ❑ វិធានការណ៍ត្រូវបានអនុវត្តដើម្បីធានាបាននូវការទទួលបានទំនិញ និងសេវាកម្មសម្រាប់អតិថិជនដែលមានបញ្ហាក្នុងការធ្វើដំណើរ និង/ឬដែលមានហានិភ័យខ្ពស់នៅទីសាធារណៈ។

**វិធានការណ៍បន្ថែមទាំងឡាយដែលខុសពីខាងលើ គួរត្រូវបានរាយនៅលើទំព័រដាច់ដោយឡែក ចំពោះមុខជំនួញដែលគួរភ្ជាប់មកជាមួយឯកសារនេះ។**

**អ្នកអាចទាក់ទងបុគ្គលខាងក្រោមជាមួយសំណួរ ឬមតិអំពីពិធីការនេះ៖**

**ឈ្មោះទំនាក់ទំនងនៃអាជីវកម្ម៖** ______________________

**លេខទូរស័ព្ទ៖** ______________________

**កាលបរិច្ឆេទកែសម្រួលចុងក្រោយ៖** ______________________

ប្រវត្តិ - មិនមានប្រសិទ្ធភាពទេ

## ដ្យាក្រាមការអង្គុយ

ដ្យាក្រាមទាំងប្រាំមួយ (6) នេះគឺសម្រាប់ប្រើជាគំរូសម្រាប់ការអង្គុយខាងក្នុង និងខាងក្រៅអគារ។ របាំងមិនអាចត្រូវបានប្រើដើម្បីកាត់បន្ថយគំលាតរវាងតុដើម្បីបង្កើនចំនួនកន្លែងអង្គុយបានឡើយ។ ការបែងចែកតុដោយមានគំលាត 8 ហ្វីត ដោយគិតពីគែមតុមួយដល់គែមតុមួយទៀត នឹងធានាបាននូវការរក្សាគំលាតរវាងកាយយ៉ាងតិច 6 ហ្វីតរវាងអតិថិជនមកពីគ្រួសារខុសៗគ្នា។

### ដ្យាក្រាម 1




**<u>ទន្ទឹមគ្នា</u>**
6 ហ្វីតរវាងកៅអី
គែមកៅអីដល់គែមកៅអីមួយទៀត

### ដ្យាក្រាម 2




**<u>ការអង្គុយបញ្ជ្រ[illegible]</u>**
6 ហ្វីតរវាង[illegible]អតិថិជននិង[illegible]កៅអីតុជាប់គ្នា
គែមកៅអីដល់គែមកៅអីមួយទៀត

### ដ្យាក្រាម 3




**<u>ទន្ទឹមគ្នា</u>**
6 ហ្វីតរវាងខ្នងកៅអីដាក់ខ្នងទល់ខ្នង

### ដ្យាក្រាម 4




**<u>ការតម្រៀបឆ្លាស់គ្នា</u>**
6 ហ្វីតរវាងកៅអីនៅចំណុចជិតបំផុត
អនុវត្តទៅលើតុគ្រប់ទម្រង់

### ដ្យាក្រាម 5



**<u>តុរចនាបទសហគមន៍ គ្មានរបាំង</u>**
6 ហ្វីតទៅកាន់សមាជិកជិតបំផុត
នៃក្រុមមួយទៀត
គែមកៅអីដល់គែមកៅអីមួយទៀត

### ដ្យាក្រាម 6




**<u>តុ booth</u>**
តុ booth អចល័ត
អាច
មានកន្លែងអង្គុយ
ដើម្បីអនុញ្ញាតឲ្យមាន
គំលាតយ៉ាងតិច 6
ហ្វីតរវាងអតិថិជន

ច្បាប់ចាស់ - មិនមានប្រសិទ្ធភាពទៀតទេ